## អគ្គិសនីកម្ពុជា
## នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

# របាយការណ៍
# ស្តីពី
# សកម្មភាពការងាររបស់
# នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ
# ឆ្នាំ២០១៣

រៀបចំដោយនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

ឆ្នាំ២០១៤

# អារម្ភកថា

របាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ឆ្នាំ២០១៣ ចេញផ្សាយឆ្នាំ២០១៤ ជារបាយការណ៍ដែលរៀបចំប្រមូលផ្តុំនូវព័ត៌មាននានាពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ គោលនយោបាយស្តីពីថាមពលកកើតឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា ការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ បេសកកម្ម សកម្មភាព និងសមិទ្ធផលនៃការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទបានអនុវត្តកន្លងមក ពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ (ពេលមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទបានដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា) រហូតដល់ចុងឆ្នាំ២០១៣។ របាយការណ៍នេះ មានគោលបំណងសម្រាប់ផ្សព្វផ្សាយជាព័ត៌មានជូនរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ អ្នកវិនិយោគ និងសាធារណជនដែលមានបំណងចង់ដឹងពីសកម្មភាពការងាររបស់មូលនិធិអគ្គិសនីភាវូប-នីយកម្មជនបទក្នុងការជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍នេះ បានរៀបចំឡើងជាភាសាខ្មែរ និងភាសាអង់គ្លេស។

មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ មានផែនការផ្សព្វផ្សាយរបាយការណ៍ស្តីពីសមិទ្ធិផលការងាររបស់ខ្លួន ១ឆ្នាំម្តង ដើម្បីឲ្យទិន្នន័យ និងព័ត៌មាននានាស្តីពីសកម្មភាពការងាររបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទឆ្លុះបញ្ចាំងទាន់សភាពការណ៍វិវឌ្ឍន៍ជាក់ស្តែង។ មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនឹងរង់ចាំដោយក្តីសោមនស្សនូវរាល់សំណូមពរ និងមតិយោបល់របស់ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ អ្នកវិនិយោគ និងសាធារណជន ដើម្បី ធ្វើឲ្យរបាយការណ៍នេះកាន់តែមានសារៈប្រយោជន៍ទៅថ្ងៃអនាគត។

មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទសង្ឃឹមថា របាយការណ៍នេះ ជាឯកសារមានតម្លៃមួយសម្រាប់ជាព័ត៌-មានស្តីពីសកម្មភាពការងាររបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ-រតនៈ**

# មាតិកា


ទំព័រ

**ជំពូកទី១ យុទ្ធសាស្ត្រ និងផែនការដើម្បីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ និងគោលនយោបាយស្តីពីថាមពលកកើតឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា ........ ៦**

១.១ យុទ្ធសាស្ត្រ និងផែនការដើម្បីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ ........ ៦
១.២ គោលនយោបាយស្តីពីថាមពលកកើតឡើងវិញ ........ ៦

**ជំពូកទី២ ព័ត៌មានស្តីពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ........ ៨**

២.១ ការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ........ ៨
២.២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ ម.អ.ជ. ........ ៨
២.៣ អាសយដ្ឋានរបស់ ម.អ.ជ. ........ ៨
២.៤ ប្រភពមូលនិធិរបស់ ម.អ.ជ. ........ ១០

**ជំពូកទី៣ ព័ត៌មានស្តីពីគោលបំណង បេសកកម្ម និងកម្មវិធីរបស់ ម.អ.ជ. សម្រាប់អភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ ........ ១១**

៣.១ គោលបំណងរបស់ ម.អ.ជ. ........ ១១
៣.២ បេសកកម្មរបស់ ម.អ.ជ. ........ ១១
៣.៣ កម្មវិធីរបស់ ម.អ.ជ. សម្រាប់អភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ ........ ១១
៣.៣.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ........ ១១
៣.៣.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ........ ១២
៣.៣.៣ កម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ១២
៣.៤ លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីរបស់ ម.អ.ជ. ........ ១៣
៣.៤.១ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ១៣
៣.៤.២ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ........ ១៣
៣.៤.៣ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ........ ១៤

**ជំពូកទី៤ ព័ត៌មានស្តីពីវឌ្ឍនភាព / សមិទ្ធផល និងការវិភាគពីកម្មវិធីនីមួយៗដែលបានអនុវត្តដោយ ម.អ.ជ. ........ ១៨**

៤.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ........ ១៨
៤.១.១ ចំនួនគោលដៅ និងសមិទ្ធផលក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ........ ១៨

៤.១.២ សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ............ ២០
៤.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ២១
៤.២.១ ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះចំនួន 12,000 ប្រព័ន្ធ ដែលបានផ្តល់ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន ............ ២១
៤.២.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ អានុភាព ៥០វ៉ាត់ ចំនួន 4,000 ប្រព័ន្ធ ............ ២៣
៤.៣ កម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ............ ២៤
៤.៣.១ ចំនួនគោលដៅ និងសមិទ្ធផល ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ............ ២៤
៤.៣.២ សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ............ ២៥
៤.៤ កម្មវិធីសិក្សាសមិទ្ធិលទ្ធភាពស្ថានីយវារីអគ្គិសនីខ្នាតតូច ............ ២៦

**ឧបសម្ព័ន្ធទី១** : ព័ត៌មានសង្ខេបស្តីពីចុះកិច្ចសន្យា តាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ............ ២៨

**ឧបសម្ព័ន្ធទី២** : ព័ត៌មានសង្ខេបស្តីពីចំនួនគ្រួសារជនបទគោលដៅ គ្រោងតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ និងស្ថានភាពបច្ចុប្បន្ន ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ............ ៣០

**ឧបសម្ព័ន្ធទី៣** : បញ្ជីឈ្មោះភូមិគ្របដណ្តប់ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ............ ៣៦

**ឧបសម្ព័ន្ធទី៤** : ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ............ ៣៧

**ឧបសម្ព័ន្ធទី៥** : បញ្ជីឈ្មោះភូមិដែលបានតម្លើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះចំនួន 12,000ប្រព័ន្ធ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន ............ ៣៧

**ឧបសម្ព័ន្ធទី៦** : ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៣ ............ ៤២

**ឧបសម្ព័ន្ធទី៧** : ព័ត៌មានស្តីពីអ្នកកាន់អាជ្ញាប័ណ្ណដែលបានចុះកិច្ចសន្យាជាមួយ ម.អ.ជ. ដើម្បីទទួលថវិកាជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ តាមខេត្តនីមួយៗ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ............ ៤៣

**ឧបសម្ព័ន្ធទី៨** : ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញគោលដៅគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួច និងស្ថានភាពបច្ចុប្បន្ន ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ តាមខេត្តនីមួយៗ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ........................................................................ ៤៦

**ឧបសម្ព័ន្ធទី៩** : បញ្ជីឈ្មោះភូមិដែលគ្របដណ្តប់ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ .......................... ៤៨

**ឧបសម្ព័ន្ធទី១០** : ផែនទីបង្ហាញពីខេត្តដែល ម.អ.ជ. បានផ្តល់ថវិកាទុនជួយសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ .................... ៥០

# បញ្ជីតារាង

**ទំព័រ**


| | | | |
|---|---|---|---|
| **តារាងទី១** | : | ព័ត៌មានស្ដីពីចំនួនគ្រួសារជនបទគោលដៅគ្រោង តភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ ជាប់កិច្ចសន្យាចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ ចំនួនគ្រួសារគោលដៅគ្រោងភ្ជាប់ចរន្តអគ្គិសនីមិនបានសម្រេចនិងត្រូវបានបញ្ចប់កិច្ចសន្យា ក្រោមកម្មវិធីផ្ដល់ចរន្ត អគ្គិសនីដល់គ្រួសារក្រីក្រ តាមខេត្តនីមួយៗ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ........ | ១៨ |
| **តារាងទី២** | : | ចំនួនភូមិសរុបនិងចំនួនភូមិ តាមខេត្តនីមួយៗដែលបានអនុវត្តកម្មវិធីផ្ដល់ចរន្ត អគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ........ | ១៩ |
| **តារាងទី៣** | : | ព័ត៌មានស្ដីពីចំនួនប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះដែលម.អ.ជ.បានលក់និង តម្លើងដល់ គ្រួសារជនបទ តាមខេត្តនីមួយៗ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន ........ | ២១ |
| **តារាងទី៤** | : | ចំនួនភូមិសរុបនិងចំនួនភូមិបានទទួលអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពល ពន្លឺព្រះអាទិត្យតាមផ្ទះ តាមខេត្តនីមួយៗ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន ........ | ២២ |
| **តារាងទី៥** | : | ព័ត៌មានសង្ខេបស្ដីពីប្រវែងខ្សែបណ្ដាញគោលដៅគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែង ខ្សែបណ្ដាញបានសាងសង់រួច ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់ អគ្គិសនីនៅតំបន់ជនបទ តាមខេត្តនីមួយៗ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ..... | ២៤ |
| **តារាងទី៦** | : | ចំនួនភូមិសរុបនិងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនី តាមខេត្តនីមួយៗ ក្រោមកម្មវិធីជួយ ទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣ ........ | ២៥ |

## ជំពូកទី១
## យុទ្ធសាស្ត្រ និងផែនការដើម្បីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ និង គោលនយោបាយស្តីពីថាមពលកកើតឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា

### ១.១ យុទ្ធសាស្ត្រ និងផែនការដើម្បីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ

ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ លើកកម្ពស់កម្រិតជីវភាពរស់នៅ និងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រជាជននៅតំបន់ជនបទ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ភាពចាំបាច់ ដើម្បីឆ្លើយតបតម្រូវការហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានរបស់ប្រជាជននៅតំបន់ជនបទដាច់ស្រយាល។ ការបង្ករលក្ខណៈឲ្យទទួលបាននូវសេវាកម្មអគ្គិសនីដែល ទុកចិត្តបាននៅតំបន់ជនបទក្នុងថ្លៃដែលអាចទទួលយកបាន គឺជាផ្នែកមួយដ៏សំខាន់នៃរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាពសង្គម។

អនុវត្តតាមរបៀបវារៈខាងលើ រាជរដ្ឋាភិបាលកម្ពុជាតំណាងដោយក្រសួងរ៉ែ និងថាមពល ដែលជាក្រសួងជំនាញបានដាក់ចេញនូវគោលដៅចំនួន ២ដំណាក់កាល សម្រាប់ជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទដូចខាងក្រោម៖

១. ដល់ឆ្នាំ២០២០ភូមិទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជានឹងមានអគ្គិសនីប្រើប្រាស់ពីប្រភពផ្សេងៗ
២. ដល់ឆ្នាំ២០៣០ យ៉ាងហោច ៧០% នៃគ្រួសារទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជានឹងមានអគ្គិសនីដែលមានគុណភាពដូចអគ្គិសនីពីបណ្តាញជាតិប្រើប្រាស់។

ជាយុទ្ធសាស្ត្រ ដើម្បីសម្រេចគោលដៅដែលបានដាក់ចេញខាងលើ រួមមាន ១- អគ្គិសនីកម្ពុជាទទួលរ៉ាប់រងខិតខំពង្រីកវិសាលភាពប្រព័ន្ធបញ្ជូនមេតង់ស្យុងខ្ពស់ (HV) ទៅគ្របដណ្តប់លើខេត្តឲ្យបានកាន់តែច្រើនទៅៗ និងប្រព័ន្ធផ្គត់ផ្គង់តង់ស្យុងមធ្យម (MV) ទៅគ្របដណ្តប់តំបន់ជនបទឲ្យបានកាន់តែឆ្ងាយទៅៗ ២- ពង្រីកតំបន់ផ្គត់ផ្គង់របស់អ្នកកាន់អាជ្ញាប័ណ្ណឲ្យគ្របដណ្តប់តំបន់ជនបទដាច់ស្រយាលឲ្យកាន់តែច្រើនទៅៗ និង ៣- ផ្តល់លទ្ធភាពឲ្យអ្នកវិនិយោគចូលរួមវិនិយោគលើវិស័យអគ្គិសនីនៅតាមតំបន់ថ្មីៗ ដែលពុំទាន់មានការផ្គត់ផ្គង់អគ្គិសនីនៅឡើយ។

### ១.២ គោលនយោបាយស្តីពីថាមពលកកើតឡើងវិញ

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិសម្រាប់អគ្គិសនីភាវូបនីយកម្មជនបទដោយប្រើថាមពលកកើតឡើងវិញចំនួន ៦ចំណុច[1] ដូចខាងក្រោម៖

១. ខិតខំខ្នះខ្នែងផ្តល់សេវាអគ្គិសនីដែលទុកចិត្តបាន មានសុវត្ថិភាព មានផលប៉ះពាល់អវិជ្ជមានតិចតួចដល់បរិស្ថាន និងតាមថ្លៃដែលអាចទទួលយកបានដល់សម្រាប់សហគមន៍ជនបទ។
២. ផ្តល់ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានប្រសិទ្ធភាព ការលើកទឹកចិត្តផ្សេងៗ និងបណ្តុះបណ្តាលផ្នែកឯកជន ដើម្បីឲ្យចូលរួមក្នុងការផ្តល់សេវាអគ្គិសនី ដោយប្រើថាមពលកកើតឡើងវិញនៅជនបទ។
៣. ធ្វើសកម្មភាពជាអ្នកសម្រួលទីផ្សារតាមរយៈការលើកទឹកចិត្តផ្សេងៗ ឲ្យមានសមភាពក្នុងការទទួលសេវាអគ្គិសនីដែលទុកចិត្តបាន មានសុវត្ថិភាព មានផលប៉ះពាល់អវិជ្ជមានក្នុងកម្រិតតិចតួចដល់បរិស្ថាន និងតាមថ្លៃដែលអាចទទួលយកបានដល់សហគមន៍ជនបទ។

---
[1] គោលនយោបាយជាតិសម្រាប់អគ្គិសនីភាវូបនីយកម្មជនបទដោយប្រើថាមពលកកើតឡើងវិញ ខែមករា ឆ្នាំ២០០៧។

៤. លើកទឹកចិត្តដល់ការផលិត ការបញ្ជូន និងការចែកចាយប្រកបដោយប្រសិទ្ធភាពនៃអគ្គិសនីដែលប្រើបច្ចេកវិទ្យាថាមពលកកើតឡើងវិញ តាមរយៈការកំណត់តារាងថ្លៃលក់មួយត្រឹមត្រូវ សមស្របតាមគោលការណ៍របស់ "ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា"។

៥. ជំរុញការអភិវឌ្ឍន៍ប្រព័ន្ធអគ្គិសនី ដោយប្រើប្រព័ន្ធថាមពលកកើតឡើងវិញទាំងឡាយណាដែលមានថ្លៃ ថោកជាងគេសម្រាប់សហគមន៍នៅតំបន់ជនបទ តាមរយៈការសិក្សាស្រាវជ្រាវ សាកល្បង និងការអភិវឌ្ឍន៍គំរូ ជាផ្នែកមួយនៃភារកិច្ចរបស់រាជរដ្ឋាភិបាលលើបច្ចេកវិទ្យាប្រព័ន្ធបណ្តាញនិងប្រព័ន្ធទោល។

៦. ជានាឲ្យមានធនធានគ្រប់គ្រាន់ យន្តការស្ថាប័នសមស្រប និងការបណ្តុះបណ្តាលនានា ដើម្បីអ្នកក្រីក្រមានលទ្ធភាពចូលរួមក្នុងការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ។

## ជំពូកទី២
## ព័ត៌មានស្តីពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

### ២.១ ការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

រាជរដ្ឋាភិបាលកម្ពុជាបានចេញព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ។ ក្នុងឆ្នាំដំបូងនៃប្រតិបត្តិការការងាររបស់ខ្លួន មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទបានប្រើប្រាស់ថវិកាដែលបានផ្តល់ដោយធនាគារពិភពលោក ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា។ បន្ទាប់ពីគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូនបានបញ្ចប់នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំផ្តល់ថវិកាសម្រាប់ដំណើរការស្ថាប័ននេះ បន្ទាប់មកនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានចេញព្រះរាជក្រឹត្យថ្មីមួយទៀតលេខ នស/រកត/០៨១២/៧៣៤ ដោយធ្វើវិសោធនកម្មមាត្រាខ្លះនៃព្រះរាជក្រឹត្យចាស់ ដោយផ្ទេរស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាវិញ ដើម្បីឲ្យកម្ពុជាខ្លួនឯងអាចម្ចាស់ការបន្តប្រតិបត្តិការការងាររបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទផង និងក៏នៅតែអាចទទួលនូវអំណោយនិងជំនួយនានាពីខាងក្រៅមកជួយអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទកម្ពុជាបានផង។ យោងតាមព្រះរាជក្រឹត្យថ្មីនេះ អគ្គិសនីកម្ពុជាបានបង្កើតនាយកដ្ឋានថ្មី[2] មួយ ហៅថា **"នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ"** បន្ទាប់ពីនេះហៅថា **"ម.អ.ជ."**។

នេះជាជំហានដ៏ធំមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទដែលនឹងទាក់ទាញ និងលើកទឹកចិត្តផ្នែកឯកជនឲ្យចូលរួមវិនិយោគក្នុងការធ្វើសេវាកម្មអគ្គិសនីនៅតំបន់ជនបទ ដើម្បីជួយជំរុញការអភិវឌ្ឍន៍នៅតំបន់ជនបទ និងដើម្បីអាចផ្តល់លទ្ធភាពឲ្យប្រជាជនក្រីក្រនៅតំបន់ជនបទកាន់តែច្រើនគ្រួសារមានអគ្គិសនីយកទៅប្រើប្រាស់សម្រាប់បំភ្លឺ ប្រកបរបរអាជីវកម្ម សិប្បកម្ម និងប្រើជាផលប្រយោជន៍ដទៃទៀត ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាដើម្បីជាផលប្រយោជន៍ទូទៅដល់សង្គមជាតិ។

### ២.២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ ម.អ.ជ.

ម.អ.ជ. ប្រតិបត្តិការស្របតាមលក្ខន្តិកៈរបស់អគ្គិសនីកម្ពុជា និងមានលក្ខណៈសង្គមកិច្ច និងមានគណនីដាច់ដោយឡែក។

### ២.៣ អាសយដ្ឋានរបស់ ម.អ.ជ.

អាសយដ្ឋាន ម.អ.ជ. ស្ថិតនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ គេហទំព័ររបស់ ម.អ.ជ. គឺ www.ref.gov.kh ។

[2] សេចក្តីសម្រេចលេខ ០៨៩៨សសអក.រប ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកំណត់ថ្នាក់អង្គភាពមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទក្នុងអង្គការលេខ និងរចនាសម្ព័ន្ធគ្រប់គ្រងអគ្គិសនីកម្ពុជា។




ម.អ.ជ. ក៏មានបណ្ណាល័យសម្រាប់សាធារណជន ដែលមានបំណងចង់យល់ដឹងពីកម្មវិធីរបស់ ម.អ.ជ. របាយការណ៍ និងការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។





## ២.៤ ប្រភពមូលនិធិរបស់ ម.អ.ជ.

ប្រភពមូលនិធិដល់ ម.អ.ជ. មានដូចខាងក្រោម៖

១. កញ្ចប់ថវិកាសង្គមកិច្ចដែលបានគ្រោងក្នុងបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងអំណោយដទៃទៀតរបស់អគ្គិសនីកម្ពុជា ប្រសិនបើមាន។

២. អំណោយ និងជំនួយឥតសំណងដែលប្រភព និងលក្ខខណ្ឌនៃការផ្តល់ត្រូវបានទទួលការឯកភាពពីក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣. ថវិកាពីរាជរដ្ឋាភិបាលកម្ពុជា។

បច្ចុប្បន្ន ថវិការបស់ ម.អ.ជ. បានមកពីអគ្គិសនីកម្ពុជា។ ក្នុងឆ្នាំ២០១៣ អគ្គិសនីកម្ពុជាបានផ្តល់ថវិកាចំនួន ៤លានដុល្លារអាមេរិក សម្រាប់ចំណាយប្រតិបត្តិការរបស់ ម.អ.ជ. និងអនុវត្តកម្មវិធីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទចំនួន៣ រួមមាន៖ ១-កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ២-កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ និង៣-កម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

## ជំពូកទី៣
## ព័ត៌មានស្តីពីគោលបំណង បេសកកម្ម និងកម្មវិធីរបស់ ម.អ.ជ. សម្រាប់អភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ

### ៣.១ គោលបំណងរបស់ ម.អ.ជ.

គោលបំណងរបស់ ម.អ.ជ.[3] មានដូចខាងក្រោម៖

១. ជំរុញឲ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឲ្យប្រជាជននៅជនបទបានទទួលអគ្គិសនីប្រើប្រាស់តាមថ្លៃ ដែលអាចជាវបានសម្រាប់សេដ្ឋកិច្ច សង្គម និងលំនៅដ្ឋាន រួមចំណែកកាត់បន្ថយភាពក្រីក្រ។

២. ជំរុញ និងលើកទឹកចិត្តផ្នែកឯកជនឲ្យចូលរួមវិនិយោគធ្វើសេវាកម្មអគ្គិសនីនៅតំបន់ជនបទ ប្រកបដោយចីរភាព ជាពិសេសក្នុងការអនុវត្តបច្ចេកវិទ្យាថ្មី និងថាមពលកកើតឡើងវិញ ដែលមានលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្មសមស្រប។

### ៣.២ បេសកកម្មរបស់ ម.អ.ជ.

ម.អ.ជ. មានបេសកកម្ម ដូចខាងក្រោម៖

១. ជម្រុញវិសាលភាពអគ្គិសនីភាវូបនីយកម្មជនបទប្រកបដោយសមភាព ដោយសម្រួលឲ្យប្រជាពលរដ្ឋជនបទទទួលបានអគ្គិសនីប្រើប្រាស់ជាលក្ខណៈសេដ្ឋកិច្ច សង្គមកិច្ច និងគ្រួសារ។

២. ផ្តល់ការគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ។

៣. ផ្តល់ការគាំទ្រ និងជួយសម្រួលដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់។

៤. ផ្តល់ការគាំទ្រ និងជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាលដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរអាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។

៥. ផ្តល់ការគាំទ្រ និងជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីឯកជននៅតំបន់ជនបទ ដែលមានអាជ្ញាប័ណ្ណស្របច្បាប់ អាចមានទុនសម្រាប់ធ្វើការវិនិយោគពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។

៦. ជម្រុញការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ដែលត្រូវបានទទួលស្គាល់ជាលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្ម។

### ៣.៣ កម្មវិធីរបស់ ម.អ.ជ. សម្រាប់អភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ

បច្ចុប្បន្ន ម.អ.ជ. កំពុងអនុវត្តកម្មវិធីមួយចំនួន ដូចខាងក្រោម៖

#### ៣.៣.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីឲ្យគ្រួសារក្រីក្រ

[3] មាត្រា៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតស្ថាប័ន ម.អ.ជ.។

រស់នៅតំបន់ជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឲ្យគ្រួសារជនបទខ្ចីយកទៅ៖ ១- បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ ២- បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ៣- ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និង៤- ចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ប្រាក់កម្ចីនេះនឹងទូទាត់តាមរយៈអ្នកផ្គត់ផ្គង់អគ្គិសនី ដែលជាអ្នកទទួលខុសត្រូវក្នុងការបង់សងត្រឡប់មក ម.អ.ជ. វិញ ដោយបានមកពីការប្រមូលពីអ្នកខ្ចីដែលត្រូវបង់សងរំលស់១ខែម្តង មក ម.អ.ជ. ក្នុងរយៈកំណត់មួយ។ ចំនួនទឹកប្រាក់កម្ចីអនុគ្រោះនេះ គឺមិនលើសពី 480,000 រៀល ក្នុង១គ្រួសារ។

### ៣.៣.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ ម.អ.ជ. នឹងជួយផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែក ក្នុង១ប្រព័ន្ធដល់គ្រួសារជនបទ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធ ហើយអ្នកទិញត្រូវបង់ថ្លៃសល់ពីការឧបត្ថម្ភធននេះ រំលស់ប្រចាំខែដោយគ្មានការប្រាក់មក ម.អ.ជ. វិញ ក្នុងរយៈពេលកំណត់មួយ។ ក្រោយពេលបង់រំលស់អស់ជាស្ថាពរ ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។

### ៣.៣.៣ កម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទដែលមានអាជ្ញាប័ណ្ណស្របច្បាប់ អាចមានទុនសម្រាប់វិនិយោគពង្រីកការផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។ លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីនេះចែកចេញជា ៣តំបន់ ផ្អែកលើដង់ស៊ីតេប្រជាពលរដ្ឋ ដូចខាងក្រោម៖

**តំបន់ទី១- តំបន់មានប្រជាពលរដ្ឋរស់នៅច្រើន ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច**

ម.អ.ជ. នឹងផ្តល់ការធានាលើការខ្ចីឥណទាន ពីធនាគារក្នុងស្រុករបស់អ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដើម្បីយកទៅវិនិយោគពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី ឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន។

**តំបន់ទី២- តំបន់មានប្រជាពលរដ្ឋរស់នៅមធ្យម ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីអាចពុំចំណេញ ប្រសិនបើអ្នកផ្គត់ផ្គង់អគ្គិសនីត្រូវបង់ការប្រាក់លើដើមទុនវិនិយោគ**

ម.អ.ជ. នឹងផ្តល់ថវិកាកម្ចីដោយពុំយកការប្រាក់ សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

**តំបន់ទី៣- តំបន់មានប្រជាពលរដ្ឋរស់នៅតិចតួច ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីមិនចំណេញ លុះត្រាមានការផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកលើទុនវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី**

ម.អ.ជ. នឹងផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកបន្ថែមពីលើប្រាក់កម្ចីឥតមានការប្រាក់ សម្រាប់អ្នកផ្គត់ផ្គង់អគ្គិសនីធ្វើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

### ៣.៤ លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីរបស់ ម.អ.ជ.

#### ៣.៤.១ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

លក្ខណៈវិនិច្ឆ័យសម្រាប់សហគ្រាសអគ្គិសនីជនបទ និងគ្រួសារជនបទ មានដូចខាងក្រោម៖

**ក. លក្ខណៈវិនិច្ឆ័យសម្រាប់សហគ្រាសអគ្គិសនីជនបទ**

លក្ខណៈវិនិច្ឆ័យសម្រាប់សហគ្រាសអគ្គិសនីជនបទ មានដូចខាងក្រោម៖

- មានអាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនីចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាប័ណ្ណមានអាណត្តិយ៉ាងតិច ៥ឆ្នាំ។
- តំបន់ជនបទដែលមានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ និងមានការផ្គត់ផ្គង់អគ្គិសនីយ៉ាងហោច ១ឆ្នាំហើយ។
- មានការកត់ត្រារបាយការណ៍គណនេយ្យត្រឹមត្រូវពីការធ្វើអាជីវកម្ម ដោយមានបង្ហាញពីការចំណេញពីអាជីវកម្មអគ្គិសនី។
- ទទួលខុសត្រូវប្រមូលប្រាក់បង់សងរំលស់ពីគ្រួសារជនបទ និងផ្ទេរចូលគណនីរបស់ ម.អ.ជ. តាមពេលកំណត់។
- ទទួលខុសត្រូវលើការបាត់បង់ថវិកាដោយសារគ្រួសារជនបទពុំបង់សងមក ម.អ.ជ. វិញ លើកលែងតែមានការឯកភាពពី ម.អ.ជ. ឲ្យលុបបំណុល។
- យល់ព្រមអនុវត្តកិច្ចសន្យា៖ ១-កិច្ចសន្យាខ្ចីឥណទានអនុគ្រោះពី ម.អ.ជ. សម្រាប់ការភ្ជាប់ចរន្តអគ្គិសនីដើម្បីប្រើប្រាស់ ២-កិច្ចសន្យារវាង ម.អ.ជ. និងសហគ្រាសអគ្គិសនីជនបទក្នុងការប្រើប្រាស់ឥណទានអនុគ្រោះ ៣-គោលការណ៍សម្រាប់អនុវត្ត ក្នុងការផ្តល់ឥណទានអនុគ្រោះដល់គ្រួសារក្រីក្រនៅជនបទ និងឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ. ក្រោមកម្មវិធីនេះ។

**ខ. លក្ខណៈវិនិច្ឆ័យសម្រាប់គ្រួសារជនបទ**

លក្ខណៈវិនិច្ឆ័យសម្រាប់គ្រួសារជនបទ មានដូចខាងក្រោម៖

- រស់នៅតំបន់ជនបទដែលមានការផ្គត់ផ្គង់អគ្គិសនីហើយ។
- គ្រួសារពុំទាន់បានតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធបណ្តាញផ្គត់ផ្គង់នៅឡើយ។
- មានលំនៅដ្ឋានឋិតថេរ និងមានសុវត្ថិភាពសម្រាប់ការតភ្ជាប់ចរន្តអគ្គិសនី។
- មានលទ្ធភាពបង់សងរំលស់មកវិញប្រចាំខែ។
- យល់ព្រមបង់សងរំលស់ប្រចាំខែក្នុងរយៈពេលយូរបំផុត ៣៦ខែ។
- យល់ព្រមអនុវត្តកិច្ចសន្យា៖ ១-កិច្ចសន្យាខ្ចីឥណទានអនុគ្រោះពី ម.អ.ជ. សម្រាប់ការភ្ជាប់ចរន្តអគ្គិសនីដើម្បីប្រើប្រាស់ ២-គោលការណ៍សម្រាប់អនុវត្តក្នុងការផ្តល់ឥណទានអនុគ្រោះដល់គ្រួសារក្រីក្រនៅជនបទ និងឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ. ក្រោមកម្មវិធីនេះ។

#### ៣.៤.២ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

លក្ខណៈវិនិច្ឆ័យសម្រាប់អនុវត្តកម្មវិធីនេះ មានដូចខាងក្រោម៖

១. គ្រួសារជនបទ និងវត្តអារាមនៅក្នុងតំបន់ជនបទដាច់ស្រយាល ដែលខ្សែបណ្តាញមិនទាន់អាចទៅដល់ក្នុងរយៈពេលយ៉ាងតិច ៥ឆ្នាំ ខាងមុខ។
២. គ្រួសារជនបទយល់ព្រមបង់សងរំលស់នៃតម្លៃសល់នៃថ្លៃប្រព័ន្ធ បន្ទាប់ពីកាត់បន្ថយប្រាក់ឧបត្ថម្ភធនមក ម.អ.ជ. វិញ ក្នុងរយៈពេល ៥ឆ្នាំ។ ការបង់ប្រាក់លើកទី១ គឺត្រូវបង់នៅថ្ងៃទទួលដាក់ឲ្យដំណើរការប្រើប្រាស់ប្រព័ន្ធដែលបានតម្លើង។ វត្តអារាមយល់ព្រមបង់តម្លៃសល់នៃថ្លៃប្រព័ន្ធ បន្ទាប់ពីកាត់បន្ថយប្រាក់ឧបត្ថម្ភធនទាំងអស់ដាច់តែម្តង មក ម.អ.ជ. វិញ នៅពេលប្រព័ន្ធតម្លើង។
៣. អ្នកទិញត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ។

### ៣.៤.៣ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីនេះ មានដូចខាងក្រោម៖

**តំបន់ទី១- តំបន់មានប្រជាពលរដ្ឋរស់នៅច្រើន ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច**

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់ទី១ មានដូចខាងក្រោម៖

១. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានអាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនី ដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាប័ណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទខ្ចីប្រាក់។
២. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានការកត់ត្រារបាយការណ៍គណនេយ្យត្រឹមត្រូវលើការធ្វើអាជីវកម្មអគ្គិសនី។
៣. ប្រាក់កម្ចីនេះ គឺសម្រាប់តែការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជន-បទដែលភ្ជាប់ពីប្រព័ន្ធបណ្តាញជាតិ ឬការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញទោល។
៤. អ្នកផ្គត់ផ្គង់អគ្គិសនីអាចប្រើប្រាស់ប្រាក់កម្ចីនេះ សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យមនិងតង់ស្យុងទាបនៅក្នុងដែនអាជ្ញាប័ណ្ណរបស់ខ្លួន ទាំងសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី និងទាំងសម្រាប់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់នៅក្នុងដែនអាជ្ញាប័ណ្ណរបស់ខ្លួន។
៥. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវយល់ព្រមចុះកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានា ជាមួយអគ្គិសនីកម្ពុជាសម្រាប់ការធានាលើការខ្ចីប្រាក់ពីធនាគារ និងជាមួយធនាគារសម្រាប់ការខ្ចីប្រាក់។
៦. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាលើលក្ខខណ្ឌនានាដែលខ្លួនត្រូវ អនុវត្តជាមួយអគ្គិសនីកម្ពុជាក្នុងកិច្ចសន្យាធានាការខ្ចីប្រាក់ពីធនាគារ រាប់ទាំងការយល់ព្រមផ្ទេរ អាជ្ញាប័ណ្ណឲ្យអគ្គិសនីកម្ពុជា ក្នុងករណីដែលខ្លួនមិនបានសងប្រាក់តាមការកំណត់។
៧. ប្រភពថវិកា គឺពីធនាគារក្នុងស្រុក។

**តំបន់ទី២- តំបន់មានប្រជាពលរដ្ឋរស់នៅមធ្យម ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីអាចពុំចំណេញ ប្រសិនបើអ្នកផ្គត់ផ្គង់អគ្គិសនីត្រូវបង់ការប្រាក់លើដើមទុនវិនិយោគ**

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់ទី២ មានដូចខាងក្រោម៖

១. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានអាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនី ដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាប័ណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទខ្ចីប្រាក់។
២. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានការកត់ត្រារបាយការណ៍គណនេយ្យត្រឹមត្រូវលើការធ្វើអាជីវកម្មអគ្គិសនី។
៣. ថវិកានេះ សម្រាប់តែវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ដែលផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្ដាញជាតិប៉ុណ្ណោះ។
៤. អ្នកផ្គត់ផ្គង់អគ្គិសនីអាចប្រើប្រាស់ប្រាក់កម្ចីនេះ សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យមនិងតង់ស្យុងទាបនៅក្នុងដែនអាជ្ញាប័ណ្ណរបស់ខ្លួន ទាំងសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី និងទាំងសម្រាប់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់ នៅក្នុងដែនអាជ្ញាប័ណ្ណរបស់ខ្លួន។
៥. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវរៀបចំផែនការអភិវឌ្ឍន៍រួមទាំងតម្លៃ និងត្រូវមានការឯកភាពលើការវិនិយោគពីអាជ្ញាធរអគ្គិសនីកម្ពុជា។
៦. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវដាក់ពាក្យស្នើសុំប្រាក់កម្ចីនេះពី ម.អ.ជ. ដោយមានភ្ជាប់មកជាមួយនូវផែនការអភិវឌ្ឍន៍លម្អិត និងត្រូវផ្តល់ច្បាប់ចម្លងឯកសារវិនិយោគ ដែលទទួលបានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា។
៧. ម.អ.ជ. ពិនិត្យពាក្យស្នើសុំ និងអនុម័តពីចំនួនទឹកប្រាក់ជំនួយសមស្របដែលត្រូវផ្តល់ឲ្យតាមដំណាក់កាលនីមួយៗ និងចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការទូទាត់ប្រាក់ និងការសងប្រាក់មកវិញ។ អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា លើលក្ខខណ្ឌនានា ដែលខ្លួនត្រូវអនុវត្តជាមួយអគ្គិសនីកម្ពុជាក្នុងកិច្ចសន្យាខ្ចីប្រាក់នេះ រាប់ទាំងការយល់ព្រមផ្ទេរអាជ្ញាប័ណ្ណឲ្យអគ្គិសនីកម្ពុជា ក្នុងករណីដែលខ្លួនមិនបានសងប្រាក់តាមការកំណត់។
៨. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវដាក់ពាក្យស្នើសុំមក ម.អ.ជ. ដោយមានភ្ជាប់នូវរបាយការណ៍វឌ្ឍនភាពមកជាមួយ ដើម្បីស្នើសុំទូទាត់ប្រាក់កម្ចីនេះ។ ម.អ.ជ. ផ្ទៀងផ្ទាត់វឌ្ឍនភាពការងារ និងធ្វើការផ្តល់តាមដំណាក់កាលៗ ដោយផ្អែកលើវឌ្ឍនភាពការងារ។ ម.អ.ជ. ត្រូវចេញលិខិតទទួលស្គាល់ពីចំនួនទឹកប្រាក់កម្ចីដែល ម.អ.ជ. បានទទួលមកវិញ នៅពេលអ្នកផ្គត់ផ្គង់អគ្គិសនីបានបង់រំលស់សងប្រាក់កម្ចីមក ម.អ.ជ. វិញគ្រប់ចំនួន។
៩. ប្រាក់កម្ចីដែលបានផ្តល់ក្រោមយន្តការនេះ ពុំមានគិតការប្រាក់ឡើយ។
១០. ចំនួនទឹកប្រាក់ឲ្យខ្ចីនេះគឺមិនលើសពី 100,000 (មួយរយពាន់) ដុល្លារអាមេរិក ក្នុង១គម្រោង។ អ្នកផ្គត់ផ្គង់អគ្គិសនីអាចស្នើសុំអនុវត្តគម្រោងថ្មីទៀតបានពី ម.អ.ជ. ពេលចាំបាច់។
១១. ក្នុងករណី អ្នកផ្គត់ផ្គង់អគ្គិសនីដែលមានអាជ្ញាប័ណ្ណហើយ ចំនួនទឹកប្រាក់កម្ចីនេះ គឺមិនលើសពី 50%នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់របស់អ្នកផ្គត់ផ្គង់អគ្គិសនីយោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ ក្នុងករណីអ្នកផ្គត់ផ្គង់អគ្គិសនីថ្មី ចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី 50% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលបានស្នើសុំរបស់អ្នកផ្គត់ផ្គង់អគ្គិសនី យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

១២. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានា ជាមួយ ម.អ.ជ.។

១៣. ប្រភពថវិកា គឺពីអគ្គិសនីកម្ពុជា។

**តំបន់ទី៣- តំបន់មានប្រជាពលរដ្ឋរស់នៅតិចតួច ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីមិនចំណេញ លុះត្រាមានការផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកលើទុនវិនិយោគហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី**

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់ទី៣ មានដូចខាងក្រោម៖

១. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានអាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនី ដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាប័ណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទផ្តល់ប្រាក់ជំនួយ។

២. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានការកត់ត្រារបាយការណ៍គណនេយ្យត្រឹមត្រូវលើការធ្វើអាជីវកម្មអគ្គិសនី។

៣. ប្រាក់ជំនួយនេះ សម្រាប់តែវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីតង់ស្យុងទាបនៅតំបន់ជនបទដែលផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ និងត្រូវបានវាយតម្លៃដោយ ម.អ.ជ. ថាជាតំបន់អនុគ្រោះ។

៤. អ្នកផ្គត់ផ្គង់អគ្គិសនី អាចវិនិយោគប្រាក់ជំនួយនេះ សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មីនៅតំបន់របស់ខ្លួន។

៥. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវរៀបចំផែនការអភិវឌ្ឍន៍រួមទាំងតម្លៃ និងត្រូវទទួលការឯកភាពលើការវិនិយោគពីអាជ្ញាធរអគ្គិសនីកម្ពុជា។

៦. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវដាក់ពាក្យស្នើសុំប្រាក់ជំនួយ និងប្រាក់ឧបត្ថម្ភធនពី ម.អ.ជ. ដោយមានភ្ជាប់មកជាមួយនូវផែនការអភិវឌ្ឍន៍លម្អិត និងត្រូវផ្តល់ច្បាប់ចម្លងឯកសារវិនិយោគដែលមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងបង្ហាញភ័ស្តុតាងសម្រាប់ការអនុម័តលើយន្តការ និងចំនួនទឹកប្រាក់ឧបត្ថម្ភធន។

៧. ម.អ.ជ.ពិនិត្យពាក្យស្នើសុំនិងអនុម័តពីចំនួនទឹកប្រាក់ជំនួយនិងប្រាក់ឧបត្ថម្ភធនសមស្របដែលត្រូវផ្តល់ឲ្យតាមដំណាក់កាលនីមួយៗ និងចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការទូទាត់ប្រាក់ និងការសងប្រាក់មកវិញ។ អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាលើលក្ខខណ្ឌនានា ដែលខ្លួនត្រូវអនុវត្តជាមួយអគ្គិសនីកម្ពុជាក្នុងកិច្ចសន្យាផ្តល់ប្រាក់ជំនួយនេះ រាប់ទាំងការយល់ព្រមផ្ទេរអាជ្ញាប័ណ្ណឲ្យអគ្គិសនីកម្ពុជា ក្នុងករណីដែលខ្លួនមិនបានសងប្រាក់តាមការកំណត់។

៨. អ្នកផ្គត់ផ្គង់អគ្គិសនី ត្រូវដាក់ពាក្យស្នើសុំមក ម.អ.ជ. ដោយមានភ្ជាប់នូវរបាយការណ៍វឌ្ឍនភាពមកជាមួយ ដើម្បីស្នើសុំទូទាត់ប្រាក់ជំនួយ។ ម.អ.ជ. ផ្ទៀងផ្ទាត់វឌ្ឍនភាពការងារ និងធ្វើការទូទាត់តាមដំណាក់កាលៗ ដោយផ្អែកលើវឌ្ឍនភាពការងារ។ ម.អ.ជ. ត្រូវចេញលិខិតទទួលស្គាល់ពីចំនួនទឹកប្រាក់កម្ចីដែល ម.អ.ជ. បានទទួលមកវិញ នៅពេលអ្នកផ្គត់ផ្គង់អគ្គិសនីបានបង់រំលស់សងប្រាក់កម្ចីមក ម.អ.ជ. វិញគ្រប់ចំនួន។ ទឹកប្រាក់ដែល ម.អ.ជ. បានឧបត្ថម្ភនៅក្នុងប្រាក់ជំនួយនេះ មិនតម្រូវឲ្យសងវិញទេ។

៩. ប្រាក់កម្ចីដែលបានផ្តល់ក្រោមយន្តការនេះ ពុំមានគិតការប្រាក់ឡើយ។

១០. ចំនួនទឹកប្រាក់ជំនួយសរុប គិតទាំងប្រាក់កម្ចី និងប្រាក់ឧបត្ថម្ភធន មិនលើសពី 100,000 (មួយរយពាន់) ដុល្លារអាមេរិក ក្នុង១គម្រោង។ អ្នកផ្គត់ផ្គង់អគ្គិសនីអាចស្នើសុំអនុវត្តគម្រោងថ្មីទៀតបានពី ម.អ.ជ. ពេលចាំបាច់។

១១. ក្នុងករណីអ្នកផ្គត់ផ្គង់អគ្គិសនីដែលមានអាជ្ញាប័ណ្ណរួចហើយ ចំនួនទឹកប្រាក់ឧបត្ថម្ភធន គឺមិនលើសពី 30% នៃតម្លៃគម្រោង និងចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី 50% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់របស់អ្នកផ្គត់ផ្គង់អគ្គិសនី យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ ក្នុងករណីអ្នកផ្គត់ផ្គង់អគ្គិសនីថ្មី ចំនួនទឹកប្រាក់ឧបត្ថម្ភធន គឺមិនលើសពី 30% នៃតម្លៃគម្រោង និងចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី 50% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលបានស្នើសុំរបស់អ្នកផ្គត់ផ្គង់អគ្គិសនី យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

១២. អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានា ជាមួយ ម.អ.ជ.។

១៣. ប្រភពថវិកា គឺពីអគ្គិសនីកម្ពុជា។

# ជំពូកទី៤
# ព័ត៌មានស្ដីពីវឌ្ឍនភាព / សមិទ្ធិផល និងការវិភាគពីកម្មវិធីនីមួយៗ ដែលបានអនុវត្តដោយ ម.អ.ជ.

## ៤.១ កម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

### ៤.១.១ ចំនួនគោលដៅ និងសមិទ្ធិផលក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

ចាប់ពីខែសីហា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ម.អ.ជ. បានចុះកិច្ចសន្យាចំនួន ២៥ ជាមួយអ្នកកាន់អាជ្ញាប័ណ្ណចំនួន ២១ (អ្នកកាន់អាជ្ញាប័ណ្ណចំនួន៤ បានអនុវត្តកិច្ចសន្យាម្នាក់២កិច្ចសន្យា) សម្រាប់តភ្ជាប់ចរន្តអគ្គិសនីថ្មីដល់គ្រួសារជនបទ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ។ ចំនួនគោលដៅត្រូវតភ្ជាប់ចរន្តអគ្គិសនីថ្មីក្រោមកិច្ចសន្យាទាំង ២៥ មានចំនួន 5,331 គ្រួសារ។ ព័ត៌មានសង្ខេបស្តីពីចុះកិច្ចសន្យា តាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី១**។

ក្នុងចំណោមកិច្ចសន្យាទាំង២៥ ខាងលើ កិច្ចសន្យាមួយចំនួនបានអនុវត្តទទួលបានជោគជ័យ១០០% ក្នុងរយៈពេលកិច្ចសន្យា ចំណែកឯកិច្ចសន្យាមួយចំនួនទៀតបានតភ្ជាប់ចរន្តអគ្គិសនីដល់គ្រួសារជនបទគោលដៅគ្រោងតភ្ជាប់ចរន្តអគ្គិសនីថ្មីបានសម្រេចតែមួយចំនួនប៉ុណ្ណោះក្នុងរយៈពេលនៃកិច្ចសន្យា និងកិច្ចសន្យាទាំងនេះត្រូវបានបញ្ចប់ស្របតាមសុពលភាពនៃអាណត្តិកិច្ចសន្យា ហើយកិច្ចសន្យាមួយចំនួនទៀតនៅកំពុងបន្តអនុវត្ត ដោយរយៈពេលនៃកិច្ចសន្យានៅមានសុពលភាព ក្រោយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ ព័ត៌មានស្តីពីចំនួនគ្រួសារជនបទគោលដៅគ្រោងតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ ចំនួនគ្រួសារគោលដៅគ្រោងភ្ជាប់ចរន្តអគ្គិសនីមិនបានសម្រេចនិងត្រូវបានបញ្ចប់កិច្ចសន្យា ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ តាមខេត្តនីមួយៗ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ មានបង្ហាញជូនក្នុង **តារាងទី១** ខាងក្រោម។

**តារាងទី១៖** ព័ត៌មានស្តីពីចំនួនគ្រួសារជនបទគោលដៅគ្រោង តភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ ចំនួនគ្រួសារគោលដៅគ្រោងភ្ជាប់ចរន្តអគ្គិសនីមិនបានសម្រេចនិងត្រូវបានបញ្ចប់កិច្ចសន្យា ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ តាមខេត្តនីមួយៗ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

| ល.រ | ខេត្ត | ចំនួនគ្រួសារជនបទគោលដៅគ្រោងតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ជាប់កិច្ចសន្យា (គ្រួសារ) | ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ (គ្រួសារ) | ចំនួនគ្រួសារគោលដៅគ្រោងតភ្ជាប់ចរន្តអគ្គិសនីមិនបានសម្រេច និងត្រូវបានបញ្ចប់កិច្ចសន្យា (គ្រួសារ) |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | 1,241 | 640 | 309 |
| ២ | បាត់ដំបង | 400 | 400 | 0 |
| ៣ | កណ្តាល | 605 | 405 | 200 |
| ៤ | ពោធិ៍សាត់ | 500 | 477 | 23 |
| ៥ | ព្រះសីហនុ | 200 | 28 | 172 |

| | | | | |
|---|---|---|---|---|
| ៦ | ស្វាយរៀង | 250 | 250 | 0 |
| ៧ | តាកែវ | 2,135 | 1,264 | 854 |
| | **សរុប** | **5,331** | **3,464** | **1,558** |

ព័ត៌មានសង្ខេបស្តីពីចំនួនគ្រួសារជនបទគោលដៅ គ្រោងតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់ និងស្ថានភាពបច្ចុប្បន្ន ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី២**។

រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ គ្រួសារជនបទបានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ មានចំនួន 3,464គ្រួសារ។តាមរបាយការណ៍ចុងក្រោយស្តីពីអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ ចំនួនមនុស្សក្នុង ១គ្រួសារនៅជនបទជាមធ្យមគឺ 4.6នាក់ ដូច្នេះចំនួនប្រជាពលរដ្ឋបានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះ គឺចំនួន 15,934 នាក់។

កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រនេះ បានផ្តល់នូវកម្លាំងរុញច្រានយ៉ាងខ្លាំងដល់សហគ្រាសអគ្គិសនីជនបទ ដោយជួយឲ្យចំនួនអ្នកប្រើប្រាស់អគ្គិសនី (គ្រួសារជនបទ) និងថាមពលអគ្គិសនីលក់ឲ្យអ្នកប្រើប្រាស់របស់សហគ្រាសអគ្គិសនីជនបទកើនឡើង។

ចំនួនភូមិសរុប និងចំនួនភូមិ តាមខេត្តនីមួយៗ ដែលបានអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ មានបង្ហាញជូនក្នុង **តារាងទី២** ខាងក្រោម។

**តារាងទី២៖** ចំនួនភូមិសរុប និងចំនួនភូមិ តាមខេត្តនីមួយៗ ដែលបានអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

| **ល.រ** | **ខេត្ត** | **ចំនួនភូមិសរុប** | **ចំនួនភូមិដែលបានអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ** |
|---|---|---|---|
| ១ | បន្ទាយមានជ័យ | 633 | 31 |
| ២ | បាត់ដំបង | 749 | 23 |
| ៣ | កណ្តាល | 1,087 | 17 |
| ៤ | ពោធិ៍សាត់ | 501 | 33 |
| ៥ | ព្រះសីហនុ | 108 | 8 |
| ៦ | ស្វាយរៀង | 690 | 29 |
| ៧ | តាកែវ | 1,116 | 108 |
| | | **សរុប** | **249** |

បញ្ជីឈ្មោះភូមិដែលគ្របដណ្តប់ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៣**។

ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៤**។

### ៤.១.២ សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

ដើម្បីជានាថា ការអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រឲ្យប្រព្រឹត្តទៅប្រកបដោយតម្លាភាព និង ត្រឹមត្រូវ និយោជិត ម.អ.ជ. បានចុះផ្ទៀងផ្ទាត់ការតភ្ជាប់ចរន្តអគ្គិសនីថ្មីដល់គ្រួសារជនបទគ្រប់សេវាករទាំងអស់ ដែល បានអនុវត្តកម្មវិធីនេះ។ រូបភាពសកម្មមួយចំនួនស្តីពីការចុះផ្ទៀងផ្ទាត់ មានបង្ហាញជូនខាងក្រោម៖

លោកស្រី អ៊ុច ប៉ោ កាន់អាជ្ញាប័ណ្ណលេខ ០៥៤អ ធ្វើសេវាកម្មអគ្គិសនីនៅឃុំព្រៃផ្តៅ ផ្នែកខ្លះនៃឃុំតាំយ៉ាប ឃុំចំប៉ា ឃុំក្តាញ់ ឃុំកំផែង ស្រុកព្រៃកប្បាស និងឃុំពន្លៃ ស្រុកអង្គរបុរី (ខេត្តតាកែវ)








## ៤.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

### ៤.២.១ ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះចំនួន 12,000 ប្រព័ន្ធ ដែលបានផ្តល់ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន

គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន ក្រោមហិរញ្ញប្បទានឥណទានរបស់ធនាគារពិភពលោក និងហិរញ្ញប្បទានឥតសំណងរបស់មូលនិធិបរិស្ថានសកល និងថវិកាបរិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាបានចប់នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២។ ក្រោយពេលគម្រោងនេះចប់ ម.អ.ជ. នៅបន្តការកាងារថែទាំប្រព័ន្ធ និងប្រមូលប្រាក់បង់សងរំលស់ថ្លៃទិញប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះត្រឡប់មក ម.អ.ជ. វិញ។ ព័ត៌មានស្តីពីចំនួនប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះដែល ម.អ.ជ. បានលក់ និងតម្លើងដល់គ្រួសារជនបទ តាមខេត្តនីមួយៗ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន មានបង្ហាញជូនក្នុង **តារាងទី៣** ខាងក្រោម។

**តារាងទី៣៖** ព័ត៌មានស្តីពីចំនួនប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះដែល ម.អ.ជ.បានលក់ និងតម្លើងដល់គ្រួសារជនបទ តាមខេត្តនីមួយៗ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន

| ល.រ | ខេត្ត | ចំនួនប្រព័ន្ធដែលបានតម្លើង | | |
|---|---|---|---|---|
| | | ៣០វ៉ាត់ | ៥០វ៉ាត់ | សរុប |
| ១ | កំពង់ស្ពឺ | 232 | 1,395 | 1,627 |
| ២ | កំពង់ធំ | 161 | 4,000 | 4,161 |
| ៣ | ក្រចេះ | 715 | - | 715 |
| ៤ | មណ្ឌលគិរី | 91 | 625 | 716 |
| ៥ | ព្រះវិហារ | 85 | 530 | 615 |
| ៦ | ពោធិ៍សាត់ | 28 | 1,298 | 1,326 |
| ៧ | រតនគិរី | - | 486 | 486 |
| ៨ | សៀមរាប | 798 | 1,556 | 2,354 |
| **សរុប** | | **2,110** | **9,890** | **12,000** |

គ្រួសារជនបទចំនួន 12,000 គ្រួសារ (១ប្រព័ន្ធក្នុង១គ្រួសារ) បានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ។ តាមរបាយការណ៍ចុងក្រោយស្តីពីអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ ចំនួនមនុស្សក្នុង ១គ្រួសារនៅជនបទជាមធ្យមគឺ 4.6 នាក់។ ដូច្នេះចំនួនប្រជាពលរដ្ឋបានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះគឺ 55,200 នាក់។

ដើម្បីធានាថា ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះដែលបានតម្លើងឲ្យគ្រួសារជនបទ ដំណើរការជាប្រក្រតី និងដើម្បីប្រមូលថវិកាបង់សងរំលស់ពីអ្នកទិញ ម.អ.ជ. បានជួលក្រុមហ៊ុនឯកជនសម្រាប់ផ្តល់សេវាកម្មនេះ។

បញ្ជីឈ្មោះភូមិដែលបានតម្លើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ចំនួន 12,000 ប្រព័ន្ធ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទនិងខ្សែបញ្ជូន មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៥**។

ចំនួនភូមិសរុប និងចំនួនភូមិបានទទួលអគ្គិសនីប្រើប្រាស់ តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ តាមខេត្តនីមួយៗ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន មានបង្ហាញជូនក្នុង **តារាងទី៤** ខាងក្រោម។

**តារាងទី៤៖** ចំនួនភូមិសរុប និងចំនួនភូមិបានទទួលអគ្គិសនីប្រើប្រាស់ តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ តាមខេត្តនីមួយៗ ក្រោមគម្រោងអគ្គិសនីការូបនីយកម្មជនបទនិងខ្សែបញ្ជូន

| **ល.រ** | **ខេត្ត** | **ចំនួនភូមិសរុប** | **ចំនួនភូមិបានទទួលអគ្គិសនីប្រើប្រាស់ តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ** |
|---|---|---|---|
| ១ | កំពង់ស្ពឺ | 1,358 | 50 |
| ២ | កំពង់ធំ | 737 | 127 |
| ៣ | ក្រចេះ | 250 | 12 |
| ៤ | មណ្ឌលគីរី | 90 | 34 |
| ៥ | ព្រះវិហារ | 208 | 31 |
| ៦ | ពោធិ៍សាត់ | 501 | 35 |
| ៧ | រតនគីរី | 240 | 19 |
| ៨ | សៀមរាប | 923 | 55 |
| | | **សរុប** | **363** |

បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ មានដូចខាងក្រោម៖

- អ្នកទិញស្នើសុំពន្យារពេលបង់ប្រាក់ ដោយសារពុំមានប្រាក់បង់។
- អ្នកទិញមានលទ្ធភាពបង់ ប៉ុន្តែស្ទាក់ស្ទើរមិនបង់ ដោយលើកហេតុផលថា អ្នកទិញផ្សេងទៀតមិនបង់។
- អ្នកទិញរុះរើប្រព័ន្ធខុសបច្ចេកទេសធ្វើឲ្យប្រព័ន្ធមិនដំណើរការត្រឹមត្រូវ និងគេចវេសមិនបង់ប្រាក់ ដោយលើកហេតុផលថា ប្រព័ន្ធខូចមិនដំណើរការ។
- អ្នកទិញធ្វើចំណាកស្រុក ដោយទុកឲ្យមនុស្សចាស់ជរា និង/ឬ ក្មេងតូចៗចាំផ្ទះ ពុំមានប្រាក់បង់។
